ÆON

# របាយការណ៍ប្រចាំឆ្នាំ ២០១១

នាការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០១១




អ៊ីអន មៃក្រូហ្វាយនែន (ខេមបូឌា)

ÆON MICROFINANCE (CAMBODIA) CO., LTD.

# មាតិកា

*ទំព័រ*


ការពិពណ៌នាអំពី អ៊ីអន ម៉ាយក្រូហ្វាយនែន(ខេមបូឌា)ប្រាយវេត ខមភេនី លីមីធីត.................... ១

របាយការណ៍គ្រប់គ្រង.......................................................................................................... ២

ភាគទុនិក........................................................................................................................ ២

ក្រុមប្រឹក្សាភិបាល.............................................................................................................. ៣

សារពីប្រធានក្រុមប្រឹក្សាភិបាល........................................................................................... ៤

របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ.... ៧

របាយការណ៍របស់សវនករឯករាជ្យ.................................................................................. ៩

របាយការណ៍ហិរញ្ញវត្ថុ..................................................................................................... ១១

តារាងតុល្យការ ................................................................................................................ ១១

របាយការណ៍លទ្ធផល....................................................................................................... ១២

របាយការណ៍បំរែបំរួលក្នុងមូលធន...................................................................................... ១៣

របាយការណ៍លំហូរសាច់ប្រាក់........................................................................................... ១៤

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ........................................................................... ១៥

# អុីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ប្រាយវេត ខមភេនី លីមីធីត

## ការពិពណ៌នាអំពីអុីអន ម៉ាយក្រូហ្វាយនែន(ខេមបូឌា)ប្រាយវេត ខមភេនី លីមីធីត

ក្រុមហ៊ុន បានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតនៅក្នុងប្រទេសកម្ពុជានាថ្ងៃទី ៥ខ តុលា ឆ្នាំ ២០១១ និង ចុះបញ្ជីការលេខ Co.២៣៨0E/២០១១ ដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១១ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្រុមហ៊ុន ត្រូវបានកាន់កាប់ទាំងស្រុង ដោយក្រុមហ៊ុន AEON Sinsap (Thailand) Public Company Limited ដែលបានចុះបញ្ជីនៅប្រទេសថៃ។ ក្រុមហ៊ុនមេ គឺ AEON Co.,Ltdដែលបាន ចុះបញ្ជីនៅប្រទេសជប៉ុន។ទស្សនៈវិជ្ជារបស់យើងគឺត្រូវ"ផ្តត់ផ្គង់របៀបរស់នៅដល់ម្ចាស់កាតទាំងឡាយនិង ធ្វើអោយបុគ្គលម្នាក់ៗអាចមានលទ្ធភាពទទួលបានឱកាសពេលអនាគតអតិបរមាជាច្រើន តាមរយៈការ ប្រើប្រាស់ឥណទានដ៏មានប្រសិទ្ធិភាព"។



## រចនាសម្ព័ន្ធគ្រប់គ្រង




## ភាគទុនិក

នៅចុងឆ្នាំ២០១១ អ៊ីអនមានមូលធនវិនិយោគចំនួន១.០០០.០០០ដុល្លារអាមេរិក។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន AEON Sinsap (Thailand) Public Company Limited ដែលបានចុះបញ្ជីនៅប្រទេសថៃ។ ក្រុមហ៊ុនមេ គឺ AEON Co., Ltd ដែលបានចុះបញ្ជីនៅប្រទេសជប៉ុន។

# ក្រុមប្រឹក្សាភិបាល



## Mr. Masao Mizuno

**មុខតំណែង** : ជាប្រធានក្រុមប្រឹក្សាភិបាល

**អាយុ** : ៥៣ឆ្នាំ

**ប្រវត្តិនៃការសិក្សា** : បញ្ចប់បរិញ្ញាប័ត្រផ្នែកច្បាប់នៅសកលវិទ្យាល័យAichi Gakuin ប្រទេស ជប៉ុន។ សញ្ញាប័ត្រនាយកគ្រប់គ្រងពីវិទ្យាស្ថានថៃនៃសមាគមនាយកគ្រប់គ្រង

**បទពិសោធន៍ការងារសំរាប់រយៈពេល៥ឆ្នាំមុន**

**១៩៩២ - បច្ចុប្បន្ន** : ជាក្រុមប្រឹក្សាភិបាលនៅ AEON Thana Sinsap (Thailand) Public Company Limited

**២០០៦ - បច្ចុប្បន្ន** : ជាក្រុមប្រឹក្សាភិបាលនៅ AEON (Thailand) Co.,Ltd.

**២០០៧ - បច្ចុប្បន្ន** : ជាក្រុមប្រឹក្សាភិបាលនៅ Serving (Thailand)Company Limited

**២០១១ - បច្ចុប្បន្ន** : ជាក្រុមប្រឹក្សាភិបាលនៅ Senior Managing Executive Officer, AEON Credit Service Co., Ltd

**២០០១-២០១១** : ជាក្រុមប្រឹក្សាភិបាលនៅ ACS Capital Corporation Limited

**២០០៥-២០១១** : ជាក្រុមប្រឹក្សាភិបាលនៅ ACS Insurance Broker (Thailand) Company Limited

**២០០៦-២០១១** : ជាក្រុមប្រឹក្សាភិបាលនៅ ACS Life Insurance Broker (Thailand) Company Limited

**២០០៧-២០១១** : ជាក្រុមប្រឹក្សាភិបាលនៅThailand Foundation



## Mr.Daisuke Maeda

**មុខតំណែង** : ជាប្រធានក្រុមប្រឹក្សាភិបាលនិងជានាយកគ្រប់គ្រង

**អាយុ** : ៣៥ឆ្នាំ

**ប្រវត្តិនៃការសិក្សា** : បញ្ចប់បរិញ្ញាប័ត្រផ្នែកទំនាក់ទំនងនៅសកលវិទ្យាល័យKansai ប្រទេសជប៉ុន

**បទពិសោធន៍ការងារសំរាប់រយៈពេល៥ឆ្នាំមុន**

**២០០៩-២០១១** : ជាប្រធាននៅ ACS Corporation Limited (ការិយាល័យតំណាងក្នុងប្រទេសកម្ពុជា)

**២០០៨-២០០៩** : ជាប្រធានជាន់ខ្ពស់ផ្នែកលក់និងទីផ្សារនៅAEON Thana Sinsap (Thailand) Public Company Limited

**២០០៦-២០០៨** : ជាជំនួយការប្រធានជាន់ខ្ពស់ផ្នែកលក់និងទីផ្សារនៅAEON Thana Sinsap (Thailand) Public Company Limited

**២005-២006** : ជាអ្នកគ្រប់គ្រងផ្នែកគ្រប់គ្រងឥណទាន នៅ AEON Thana Sinsap (Thailand) Public Company Limited



## លោក អោម សេងបូរ៉ា

**មុខតំណែង** : ជាអភិបាលឯករាជ្យ

**អាយុ** : ៣៩ឆ្នាំ

**ប្រវត្តិនៃការសិក្សា** :បញ្ចប់អនុបណ្ឌិតនៅសកលវិទ្យាល័យ Preston សហរដ្ឋអាមេរិក

**បទពិសោធន៍ការងារសំរាប់រយៈពេល៥ឆ្នាំមុន**

**២០១០ - បច្ចុប្បន្ន** : ជាប្រធានវិទ្យាស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា

**២០០៤-២០០៩** :ប្រធាននាយកប្រតិបត្តិនៅVisionFundស្ថាប័នមីក្រូហិរញ្ញវត្ថុ

## សារពីក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ **អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)** ( "ក្រុមហ៊ុន") បង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ និងសំរាប់អំឡុងពេលចាប់ពីថ្ងៃទី ៥ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១។

សកម្មភាពចំបងរបស់ក្រុមហ៊ុនមានដូចខាងក្រោមៈ

- ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដូចជា ផ្តល់នូវប្រាក់កំចី និងទទួលប្រាក់បញ្ញើ
- សេវាកម្មផ្តល់ប្រាក់កំចីក្នុងទំរង់ជាការទិញបណ្តាក់ និងឥណទាន
- កំចីមូលនិធិ និងទទួលប្រាក់បញ្ញើដោយអនុលោមតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា និង
- សេវាកម្មពាក់ពន្ធ័ដទៃទៀតដែលត្រូវអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា

## លទ្ធផលពីប្រតិបត្តិការ

ខាតក្រោយបង់ពន្ធនៃក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទគឺ ១០០.៤២៦ដុល្លារអាមេរិក ឬ ៤០៥ .៦២១.០០០ រៀល។

## ទុនបំរុង និងសំវិធានធន

មិនមានបំរែបំរួលជាសារវ័ន្តលើ ឬ ពីទុនបំរុង និងសំវិធានធនសំរាប់ការិយបរិច្ឆេទ លើកលែងតែបំរែបំរួលដែលត្រូវបានលាតត្រដាងបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងអគ្គនាយកបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថានីតិវិធីពាក់ព័ន្ធជាមួយការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានអាក្រក់ និងសង្ស័យត្រូវបានយកមកអនុវត្ត ហើយនិងជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចោលហើយសំវិធានធនត្រូវបានប៉ាន់ស្មានយ៉ាងគ្រប់គ្រាន់សំរាប់ឥណទានអាក្រក់ និងសង្ស័យ។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ អគ្គនាយកសូមធ្វើការអះអាងថាពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលអោយចំនួនទឹកប្រាក់នៃឥណទានអាក្រក់ ដែលបានលុបចោលឬ ចំនួនទឹកប្រាក់សំវិធានធនលើបំណុលអាក្រក់ និងសង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវ័ន្តនោះទេ។

## ទ្រព្យសកម្មចរន្ត

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយទ្រព្យសកម្មចរន្ត (លើកលែងតែ ករណីពាក់ព័ន្ធជាមួយឥណទាន) ដែលមិនទំនងទទួលស្គាល់ក្នុងតំលៃដើម ដូចដែលបានបង្ហាញក្នុងបញ្ជីការគណនេយ្យរបស់ក្រុមហ៊ុន ប៉ុន្តែត្រូវបានគេកត់ត្រានូវតំលៃដែលរំពឹងទុកថានឹងត្រូវទទួលយកបាន។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាល សូមធ្វើការអះអាងថា ពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលអោយការកំណត់តំលៃនៃទ្រព្យសកម្មរយៈពេលខ្លី នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានការយល់ច្រឡំ និង មានភាពមិនសមស្របជាសារវន្តនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលសូមធ្វើការអះអាង ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង និងធ្វើអោយប៉ះពាល់ដល់វិធីសាស្ត្រវាយតំលៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនាំអោយមានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- គ្មានការទទួលខុសត្រូវដែលកើតចេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន ក្នុងការធានាបំណុលរបស់បុគ្គលដទៃ នាការិយបរិច្ឆេទចុងគ្រានៃរបាយការណ៍នេះ និង
- គ្មានបំណុលយថាហេតុទាក់ទងដល់ក្រុមហ៊ុនដែលបានកើតឡើងចាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទបញ្ចប់ ដល់ការិយបរិច្ឆេទនៃរបាយការណ៍នេះក្រៅពីបំណុល ដែលមានទំនាក់ទំនងជាមួយសកម្មភាពពាណិជ្ជកម្ម ធម្មតារបស់ក្រុមហ៊ុននោះទេ

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាលគ្មានបំណុលយថាហេតុ ឬ បំណុលផ្សេងៗរបស់ក្រុមហ៊ុនដែលអាច ឬ ទំនងក្លាយជាកាតព្វកិច្ចក្នុងអំឡុង ១២ខែទេ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍ដែនឹងមាន ឬ អាចមាន ផលប៉ះពាល់ជាសារវន្ត ទៅលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុល ទាំងនោះក្លាយជាបំណុលពិត។

**ចំរេបំរួលនៃកាលៈទេសៈ**

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាល សូមធ្វើការអះអាង ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង និង ធ្វើអោយប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនាំអោយមានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ ។

**សមាសធាតុមិនប្រក្រតី**

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនបានរងនូវឥទ្ធិពលពីប្រតិបត្តិការ ហេតុការណ៍ជាសារវន្ត ឬ ហេតុការណ៍មិនប្រក្រតីឡើយ។ លើសពីនេះទៅទៀត ក៏មិនមានកើតឡើងក្នុងអំឡុងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទរបាយការណ៍នៃធាតុ ឬ ហេតុការណ៍ណាមួយដែល ធ្វើអោយប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទហិរញ្ញវត្ថុ បច្ចុប្បន្នដែលរបាយការណ៍នេះបានធ្វើឡើង។

**ហេតុការណ៍ក្រោយកាលបរិច្ឆេទតារាងតុល្យការ**

ពុំមានហេតុការណ៍ណាមួយដែលបានកើតឡើងក្រោយកាលបរិច្ឆេទតារាងតុល្យការដែលតំរូវអោយបង្ហាញ ឬ កែតំរូវ ក្រៅពីហេតុការណ៍ដែលបានបង្ហាញក្នុង កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុឡើយ។

**ក្រុមប្រឹក្សាភិបាល**

សមាសភាពនៃក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទនេះ និងនៅកាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន ៖

| | |
|---|---|
| Mr. Masao Mizuno | ប្រធានក្រុមប្រឹក្សាភិបាល |
| Mr. Daisuke Maeda | អនុប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង |
| លោក អោម សេងបូរ៉ា | អភិបាលឯករាជ្យ |

**សវនករ**

ក្រុមហ៊ុនសវនករឯករាជ្យ **Ernst & Young** បានសំដែងនូវឆន្ទៈ ដើម្បីទទួលយកការតែងតាំងជាសវនករជាថ្មីម្តងទៀតសំរាប់ការិយបរិច្ឆេទបន្ទាប់។

## ភាគកម្មរបស់អភិបាល

ពុំមានអភិបាលណាម្នាក់មានភាគកម្មរបស់ក្រុមហ៊ុន។ មិនមានកិច្ចព្រមព្រៀងណាមួយដែលមានស្រាប់ (ក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង) ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចបង្កលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍ពីក្រុមហ៊ុន ឬ របស់សាជីវកម្មដទៃ ។

## អត្ថប្រយោជន៍របស់អភិបាល

ក្នុងអំឡុងពេល និងនៅចុងការិយបរិច្ឆេទនេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលមានស្រាប់ (ក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង)ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចបង្កលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជា ការទិញ ភាគហ៊ុន ឬ ប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬ របស់សាជីវកម្មដទៃ។

ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈហេតុផលនៃកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬ ជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះជាសមាជិកក្រុមប្រឹក្សាភិបាល ឬក៏ ជាមួយក្រុមហ៊ុនណាមួយដែល អភិបាលនោះមានផលប្រយោជន៍ហិរញ្ញវត្ថុជាសារវន្ត លើកលែងតែអត្ថប្រយោជន៍ទាំងឡាយណាដែលត្រូវបានលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ និងលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងរបាយការណ៍លំហូរសាច់ប្រាក់សំរាប់ចុងការិយបរិច្ឆេទ។

ក្រុមប្រឹក្សាភិបាលត្រូតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដែលធ្វើឡើងដោយថ្នាក់ដឹកនាំបានតំរូវអោយ ៖

- អនុម័តគោលនយោបាយគណនេយ្យសមស្រប ដោយតំរូវអោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និង ប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍
- អនុវត្តតាមបទបញ្ញត្តិ និងសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬ ប្រសិនបើមានគំលាតនៃការអនុវត្តបទបញ្ញត្តិ និងសេចក្តីណែនាំហើយនិងស្តង់ដារដែលជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គំលាតទាំងនោះ ត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- រក្សាទុកបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពលើកលែងតែក្នុងករណីដែលក្រុមហ៊ុនរួមមិនអាចបន្តសកម្មភាពអាជីវកម្មនាអនាគត
- បង្កើតគោលនយោបាយទាំងមូលសំរាប់ក្រុមហ៊ុនអនុម័តរាល់ការសំរេចចិត្តនិងសកម្មភាពទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ដែលមានឥទ្ធិពលលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃ ប្រតិបត្តិការរបស់ក្រុមហ៊ុនហើយ និងធានាថាគោលនយោបាយ និងការសំរេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថា បញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអោយបានត្រឹមត្រូវសមហេតុផលគ្រប់ពេលហើយនិងធានាថា បញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ ក្រុមប្រឹក្សាភិបាលក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុនហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និងស្វែងរកកំហុសចេតនាហើយនិងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថាក្រុមហ៊ុនបានអនុវត្តតាមល័ក្ខខ័ណ្ឌតំរូវចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងក្រុមប្រឹក្សាភិបាលសូមអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់ជាមួយនេះផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវនៃរបាយការណ៍តារាងតុល្យការរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ និងរបាយការណ៍លទ្ធផល ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់សំរាប់ចុងការិយបរិច្ឆេទ ដោយអនុលោមតាមបទបញ្ញត្តិ និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ។

តំណាងនៃក្រុមប្រឹក្សាភិបាល

__________________________

Daisuke Maeda

អនុប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

ធ្វើនៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២

## របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះៈ ក្រុមប្រឹក្សាភិបាលនៃ អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ប្រាយវេត ខមភេនី លីមីធីត

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ប្រាយវេត ខមភេនី លីមីធីត** ("ក្រុមហ៊ុន") រួមមាន តារាងតុល្យការ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ និង របាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលក្នុងមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ហើយនិង គោលនយោបាយគណនេយ្យសំខាន់ៗ និងកំណត់សំគាល់ផ្សេងៗទៀត ( រួមគ្នាហៅថា "របាយការណ៍ហិរញ្ញវត្ថុ")។

## ការទទួលខុសត្រូវរបស់ ថ្នាក់ដឹកនាំចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ថ្នាក់ដឹកនាំក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជាហើយនិងបទបញ្ញត្តិ និងគោលនយោបាយ ណែនាំដែលពាក់ព័ន្ធចេញដោយធនាគារជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលថ្នាក់ដឹកនាំគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវ័ន្តដែលបណ្តាលមកពីការក្លែងបន្លំ ការភាន់ច្រឡំ។

## ការទទួលខុសត្រូវរបស់សវនករឯករាជ្យ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយផ្អែកលើមូលដ្ឋាននៃការងារសវនកម្ម។ យើងខ្ញុំបានធ្វើការងារសវនកម្មដោយអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនេះតំរូវអោយ យើងខ្ញុំអនុវត្តតាមតំរូវការនៃក្រមសីលធម៌និងរៀបចំផែនការ និងបំពេញការងារសវនកម្ម ដើម្បីទទួលបាននូវការធានាសមហេតុផល ដើម្បីអះអាងថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវ័ន្តឡើយ។

ការងារសវនកម្មយើងខ្ញុំរួមមាន ការអនុវត្តនីតិវិធីទាំងឡាយដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅ

នឹងបរិមាណទឹកប្រាក់ និងការបង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ រាល់នីតិវិធីដែលយើងខ្ញុំបានជ្រើសរើសខាងលើ គឺពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់សវនករ ដោយរាប់បញ្ចូលនូវការវាយតំលៃហានិភ័យលើភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

ក្នុងការវាយតំលៃលើហានិភ័យទាំងនោះ យើងខ្ញុំបានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំ និង ការបង្ហាញពីទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែការវាយតំលៃទាំងនេះ មិនមែនសំរាប់គោលបំណងក្នុងការបញ្ចេញមតិយោបល់លើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។ ការងារសវនកម្មរបស់យើងខ្ញុំ ក៏រួមបញ្ចូលផងដែរនូវការវាយតំលៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និង ភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយថ្នាក់ដឹកនាំព្រមទាំងការវាយតំលៃលើការបង្ហាញគ្រប់គ្រាន់នៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល

យើងជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានលក្ខណៈគ្រប់គ្រាន់និង សមហេតុសមផល ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## មតិយោបល់របស់សវនករ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការហើយនិងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោម ទៅតាមស្តង់ដារគណនេយ្យកម្ពុជាហើយនិងបទបញ្ញត្តិនិងគោលការណ៍ណែនាំដែលពាក់ព័ន្ធចេញដោយធនាគារជាតិនៃកម្ពុជា។



Maria Cristina M. Calimbas

**Ernst & Young (Cambodia) Ltd.**

ក្រុមហ៊ុនគណនេយ្យជំនាញ និង សវនកម្មប្រតិស្រុត

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២

# អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)
# តារាងតុល្យការ

នាចុងការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

| | *កំណត់សំគាល់* | *២០១១* | |
|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | | *(កំណត់សំគាល់លេខ ២.៣.១)* |
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ | | ៤៨១ | ១.៩៤៣ |
| សមតុល្យជាមួយធនាគារជាតិ | ៣ | ៨៣៧.០១០ | ៣.៣៨០.៦៨៣ |
| សមតុល្យជាមួយធនាគារផ្សេងៗ | ៤ | ៥៨.៦៧៦ | ២៣៦.៩៩២ |
| ឥណទានទៅអតិថិជន | ៥ | ៣៣.០០៤ | ១៣៣.៣០៣ |
| ទ្រព្យសកម្មផ្សេងៗ | ៦ | ២៦.៥០៨ | ១០៧.០៦៦ |
| អចលនទ្រព្យ និងបរិក្ខារ | ៧ | ៧៧.៩៧២ | ៣១៤.៩២៩ |
| **សរុបទ្រព្យសកម្ម** | | **១.០៣៣.៦៥១** | **៤.១៧៤.៩១៦** |
| **ទ្រព្យអកម្ម និង មូលនិធិម្ចាស់ភាគហ៊ុន** | | | |
| **ទ្រព្យអកម្ម** | | | |
| គណនីត្រូវសង | ៨ | ៨៣.៨៦១ | ៣៣៨.៧១៤ |
| គណនីបំណុលពន្ធ | | ៤.៣៥៥ | ១៧.៥៩០ |
| ជំពាក់ទៅភាគីពាក់ព័ន្ធ | **១៣** | ៤៥.៨៦១ | ១៨៥.២៣៣ |
| **សរុបទ្រព្យអកម្ម** | | **១៣៤.០៧៧** | **៥៤១.៥៣៧** |
| **មូលនិធិម្ចាស់ភាគហ៊ុន** | | | |
| មូលធនដែលបានវិនិយោគ | ៩ | ១.០០០.០០០ | ៤.០៣៩.០០ |
| ខាតសុទ្ធសំរាប់ការិយបរិច្ឆេទ | | (១០០.៤២៦) | (៤០៥.៦២១) |
| **សរុបមូលនិធិម្ចាស់ភាគហ៊ុន** | | **៨៩៩.៥៧៤** | **៣.៦៣៣.៣៧៩** |
| **សរុបទ្រព្យអកម្ម និង មូលនិធិម្ចាស់ភាគហ៊ុន** | | **១.០៣៣.៦៥១** | **៤.១៧៤.៩១៦** |

# អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)

## របាយការណ៍លទ្ធផល

សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ៥ ខែ តុលា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

| | *កំណត់សំគាល់* | *២០១១* | |
|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | | *(កំណត់សំគាល់លេខ ២.៣.១)* |
| **ចំណូលប្រតិបត្តិការ** | | | |
| ចំណូលពីការប្រាក់ | | ៩៥ | ៣៨៤ |
| ចំណូលកម្រៃឈ្នួល និងកម្រៃជើងសារ | | ៦៣ | ២៥៤ |
| **ចំណូលប្រតិបត្តិការសរុប** | | **១៥៨** | **៦៣៨** |
| ចំណាយប្រតិបត្តិការ | ១០ | (១០០.៥៨២) | (៤០៦.២៥១) |
| **ខាតមុនពេលបង់ពន្ធ** | | (១០០.៤២៤) | (៤០៥.៦១៣) |
| ពន្ធលើប្រាក់ចំណេញ | ១១ | (២) | (៨) |
| **ខាតសុទ្ធសំរាប់ការិយបរិច្ឆេទ** | | **(១០០.៤២៦)** | **(៤០៥.៦២១)** |

## អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)

## របាយការណ៍បំរែបំរួលក្នុងមូលធន

សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ៥ ខែ តុលា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

| | *កំណត់ សំគាល់* | *មូលធន ដុល្លារអាមេរិក* | *ខាតសុទ្ធ ដុល្លារអាមេរិក* | *សរុប ដុល្លារអាមេរិក* |
|---|---|---|---|---|
| សមតុល្យនៅ ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១១ | | | | |
| មូលធន | | ១.០០០.០០០ | - | ១.០០០.០០០ |
| ខាតសុទ្ធសំរាប់ការិយបរិច្ឆេទ | | - | (១០០.៤២៦) | (១០០.៤២៦) |
| **សមតុល្យនៅ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១** | | **១.០០០.០០០** | **(១០០.៤២៦)** | **៨៩៩.៥៧៤** |
| **សមមូលពាន់រៀល (កំណត់សំគាល់ ២.៣.១)** | | **៤.០៣៩.០០០** | **(៤០៥.៦២១)** | **៣.៦៣៣.៣៧៩** |

**អ៊ីអន ម៉ាយគ្រូហ្វាយនែន (ខេមបូឌា)**

## របាយការណ៍លំហូរសាច់ប្រាក់

សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ៥ ខែ តុលា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

| | *កំណត់សំគាល់* | *២០១១* | |
|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | | *(កំណត់សំគាល់លេខ ២.៣.១)* |
| **សកម្មភាពប្រតិបត្តិការ** | | | |
| ខាតមុនបង់ពន្ធ | | (១០០.៤២៤) | (៤០៥.៦១៣) |
| កែតំរូវសំរាប់រំលស់ | | ៣.៩៥១ | ១៥.៩៥៨ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ មុនបំរែបំរួល ទ្រព្យសកម្ម និង ទ្រព្យអកម្ម | | (៩៦.៤៧៣) | (៣៨៩.៦៥៥) |
| កំនើនទ្រព្យសកម្ម និង ទ្រព្យអកម្មប្រតិបត្តិការ | | | |
| សមតុល្យនៅធនាគារជាតិ | | (៥០.០០០) | (២០១.៩៥០) |
| ឥណទានទៅអតិថិជន | | (៣៣.០០៤) | (១៣៣.៣០៣) |
| ទ្រព្យសកម្មផ្សេងៗ | | (២៦.៥០៨) | (១០៧.០៦៦) |
| គណនីត្រូវសង | | ៨៣.៨៦១ | ៣៣៨.៧១៤ |
| គណនីបំណុលពន្ធ | | ៤.៣៥៣ | ១៧.៥៨២ |
| ជំពាក់ទៅភាគីពាក់ព័ន្ធ | | ៤៥.៨៦១ | ១៨៥.២៣៣ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | **(៧១.៩១០)** | **(២៩០.៤៤៥)** |
| **ចលនាសាច់ប្រាក់មកពីសកម្មភាពវិនិយោគ** | | | |
| ការទិញអចលនទ្រព្យ និងបរិក្ខារ | ៧ | **(៨១.៩២៣)** | **(៣៣០.៨៨៧)** |
| **ចលនាសាច់ប្រាក់បានមកពីសកម្មភាពហិរញ្ញវត្ថុ** | | | |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | ៩ | **១.០០០.០០០** | **៤.០៣៩.០០០** |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ៤ | **៨៤៦.១៦៧** | **៣.៤១៧.៦៦៨** |

**អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)**

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាការិយបរិច្ឆេទថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១១ និងសំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ៥ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១

## ១. ព័ត៌មានអំពីក្រុមហ៊ុន

**អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា)** ( ហៅថា **"ក្រុមហ៊ុន"** ) បានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានបង្កើតឡើង និងចុះបញ្ជី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

*ការបង្កើត និងប្រតិបត្តិការ*

ក្រុមហ៊ុន បានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតនៅក្នុងប្រទេសកម្ពុជានាថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១១ ចុះបញ្ជីការលេខ Co.២៣៨0E/២០១១ ដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១១ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្រុមហ៊ុន ត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន AEON Sinsap (Thailand) Public Company Limited ដែលបានចុះបញ្ជីនៅប្រទេសថៃ។ ក្រុមហ៊ុនមេ គឺ AEON Co., Ltd ដែលបានចុះបញ្ជីនៅប្រទេសជប៉ុន។

សកម្មភាពចំបងរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

- ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដូចជា ផ្តល់នូវប្រាក់កំចី និងទទួលប្រាក់បញ្ញើ
- សេវាកម្មផ្តល់ប្រាក់កំចីក្នុងទំរង់ជាការទិញបណ្តាក់ និងឥណទាន
- កំចីមូលនិធិ និងទទួលប្រាក់បញ្ញើដោយអនុលោមតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា និង
- សេវាកម្មពាក់ពន្ធ័ដទៃទៀតដែលត្រូវអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា

*មូលធនវិនិយោគ*

មូលធនដែលបានវិនិយោគរបស់ក្រុមហ៊ុន នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ មានចំនួន ១.០០០.០០០ដុល្លារអាមេរិក ឬ ៤.០៣៩.០០០.០០០រៀល ។

*ក្រុមប្រឹក្សាភិបាល*

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទនេះ និង នៅកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន:

Mr. Masao Mizuno ប្រធានក្រុមប្រឹក្សាភិបាល

Mr. Daisuke Maeda អនុប្រធានក្រុមប្រឹក្សាភិបាល និង នាយកគ្រប់គ្រង

លោក អោម សេងបូរ៉ា អភិបាលឯករាជ្យ

**ទីតាំង**

ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនមានអាស័យដ្ឋាននៅអគារលេខ ៣២០ មហាវិថីព្រះមុនីវង្ស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

***និយោជិក***

និយោជិកទាំងអស់របស់ក្រុមហ៊ុននាកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ មានចំនួន ២៦ នាក់។

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ

## ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំតាម វិធីសាស្រ្តថ្លៃដើមប្រវត្តិសាស្រ្ត។ រូបិយប័ណ្ណជាតិរបស់កម្ពុជាគឺខ្មែររៀល។ ទោះជាយ៉ាងណាក្រុមហ៊ុនធ្វើប្រតិបត្តិការ និងរក្សាការកត់ត្រាគណនេយ្យដំបូងជាដុល្លារអាមេរិកដូច្នេះថ្នាក់គ្រប់គ្រងក្រុមហ៊ុន បានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណ សំរាប់ការបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយសារតែរូបិយប័ណ្ណទាំងនោះឆ្លុះបញ្ចាំងពីភាពជាក់ស្តែងសេដ្ឋកិច្ចនៃព្រឹត្តិការណ៍
និងកាលៈទេសៈសំខាន់ៗរបស់ក្រុមហ៊ុន។

ប្រតិបត្តិការក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក ត្រូវបានប្រែសំរួលទៅជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃធ្វើប្រតិបត្តិការ។ ទ្រព្យសកម្ម និង ទ្រព្យអកម្មដែលចារឹកក្រៅពីដុល្លារអាមេរិកនាការិយបរិច្ឆេទតារាងតុល្យការ ត្រូវបានប្រែសំរួលជាដុល្លារអាមេរិកដោយប្រើអត្រាប្តូរប្រាក់នៅការិយបរិច្ឆេទតារាងតុល្យការ។ កំរិតលំអៀងនៃប្រែសំរួលអត្រាប្តូរប្រាក់ត្រូវបានបង្ហាញក្នុងរបាយការណ៍លទ្ធផល។

*ឆ្នាំសារពើពន្ធ*

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញផ្អែកលើឆ្នាំសារពើពន្ធដំបូងដែលចាប់ផ្តើមពីថ្ងៃទី ៥ ខែ តុលា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១។ ការិយបរិច្ឆេទសារពើពន្ធក្រោយៗរបស់ក្រុមហ៊ុន គឺចាប់ផ្តើម ពីថ្ងៃទី ១ ខែ មករា និងបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ។

### *២.១.១ ការបង្ហាញរបាយការហិរញ្ញវត្ថុ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យ កម្ពុជា និង បទបញ្ញត្តិនិងសេចក្តីណែនាំដែលពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយនិងការប្រើប្រាស់ ត្រូវបានធ្វើឡើងសំរាប់អ្នកដែលមាន ចំណេះដឹងអំពីគោលការណ៍, នីតិវិធី និងការអនុវត្តន៍របស់គណនេយ្យកម្ពុជា ព្រមទាំងមិនមាន បំណងបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និង លទ្ធផលប្រតិបត្តិការ និង លំហូរសាច់ប្រាក់ដោយ អនុលោមតាមគោលការណ៍គណនេយ្យ និង ការអនុវត្តន៍ដែលទទួលស្គាល់ជាទូទៅនៅប្រទេស ផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយគណនេយ្យបង្ហាញខាងក្រោមត្រូវបានក្រុមហ៊ុនអនុវត្តជាប្រចាំក្នុងអំឡុងការិយ បរិច្ឆេទ។

## ២.២ សេចក្តីវិនិច្ឆ័យគណនេយ្យ និង ការប៉ាន់ស្មានសំខាន់ៗ

ក្នុងការអនុវត្តន៍គោលនយោបាយគណនេយ្យ ក្រុមហ៊ុនបានប្រើប្រាស់ការវិនិច្ឆ័យ និង ប៉ាន់ស្មាន ក្នុងការកំណត់ទឹកប្រាក់ដែលទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

### *២.២.១ ការស្រុតចុះនៃតំលៃរបស់ឥណទានទៅអតិថិជន*

ពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គុណភាពនៃឥណទានត្រូវបានត្រួតពិនិត្យ និង វាយតំលៃដើម្បី កំណត់ចំណាត់ថ្នាក់ និង កំរិតស្រុតចុះនៃតំលៃ ដូចមានក្នុង កំណត់សំគាល់ ២៣.៧.១។

## ២.៣ សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

### *២.៣.១ ការប្រែសំរូលរូបិយប័ណ្ណបរទេស*

រូបិយប័ណ្ណក្នុងការបង្ហាញនិងប្រតិបត្តិការរបស់ក្រុមហ៊ុនគឺ ដុល្លារអាមេរិក។

ការប្រែសំរួលពីដុល្លារអាមេរិកទៅជារៀល គឺសំរាប់ការប្រើប្រាស់របស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ និង ផ្អែកលើមូលដ្ឋានអត្រា ១ដុល្លារអាមេរិក ស្មើនឹង ៤.០៣៩រៀល ដែលបានចេញផ្សាយដោយ ធនាគារជាតិនៃកម្ពុជា។ ការប្រែសំរួលនេះ មិនត្រូវបានយកទៅប្រើប្រាស់ជាការបង្ហាញអោយ ទឹកប្រាក់ជារៀលទាំងស្រុង ឬ បំលែងជារៀលក្នុងអត្រាផ្សេងទៀតឡើយ។

### ២.៣.២ ការស្រុតចុះនៃតំលៃទ្រព្យហិរញ្ញវត្ថុ

ក្រុមហ៊ុនប៉ាន់ប្រមាណរៀងរាល់កាលបរិច្ឆេទតារាងតុល្យការថា តើមានអំណះអំណាងឥតលំអៀងណាមួយអាចអះអាងថា ទ្រព្យសកម្មហិរញ្ញវត្ថុបានស្រុតចុះនៃតម្លៃ។ ទ្រព្យសកម្មហិរញ្ញវត្ថុតំរូវអោយកែសំរួលតំលៃ ប្រសិនបើមានអំណះអំណាងច្បាស់លាស់ណាមួយដែលជាលទ្ធផលនៃហេតុការណ៍ខាតបង់មួយឬក៏ច្រើនបានកើតឡើងបន្ទាប់ពីទ្រព្យសកម្មត្រូវបានទទួលស្គាល់ ហើយការខាតបង់នោះនឹងប៉ះពាល់ដល់ការព្យាករណ៍លំហូរសាច់ប្រាក់នាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលអាចប៉ាន់ស្មានបានពិតប្រាកដ។

អំណះអំណាងនៃការស្រុតចុះនៃឥណទានរួមមានការតាមដានអ្នកខ្ចីប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុ មិនមានលទ្ធភាព ឬ ល្មើសនឹងការទូទាត់ការប្រាក់ ឬ ប្រាក់ដើម , ឱកាសក្ស័យធន ឬ ការកែប្រែ ទំរង់ហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត រួមមានការសង្កេតដែលបង្ហាញថា ការធ្លាក់ចុះលំហូរសាច់ប្រាក់ នាពេលអនាគតអាចវាស់វែងបានដូចជាការប្រែប្រួលនៃការទូទាត់ ឬ ស្ថានភាពសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងលទ្ធភាពទូទាត់។ យ៉ាងណាមិញ ក្រុមហ៊ុនត្រូវអនុវត្តការចាត់ថ្នាក់ឥណទាន និង សំវិធានធនអប្បបរមាដោយយោងតាមធនាគារជាតិនៃកម្ពុជា ដូចមានក្នុងកំនត់សំគាល់ ២.៣.៧.១។

### ២.៣.៣ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានកាត់កងគ្នា ហើយចំនួនទឹកប្រាក់សុទ្ធត្រូវបានបង្ហាញក្នុងតារាងតុល្យការតែក្នុងករណី ដែលមានសិទ្ធិស្របច្បាប់ ដើម្បីកាត់កងទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ ហើយមានបំណងទូទាត់តាមមូលដ្ឋានសុទ្ធ ឬ លក់ទ្រព្យសកម្ម និង ទូទាត់បំណុលនៅពេលទន្ទឹមគ្នានោះ។ ជាទូទៅនេះមិនមែនជាករណីរបស់កិច្ចព្រមព្រៀងកាត់កងឡើយ ហើយទ្រព្យសកម្ម និងបំណុលពាក់ព័ន្ធត្រូវបានបង្ហាញ ជាទឹកប្រាក់ដុលក្នុងតារាងតុល្យការ។

### ២.៣.៤ ភតិសន្យា

ការចំណាយទៅលើភតិសន្យា ត្រូវបានគិតបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល តាមអត្រាថេរ ស្របតាមថេរវេលានៃការជួល។

### ២.៣.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សំរាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់សុទ្ធ សមតុល្យនៅធនាគារគណនីចរន្ត និង ការវិនិយោគរយៈពេលខ្លី ដែលងាយប្តូរជាសាច់ប្រាក់បានឆាប់រហ័ស និងជាក់លាក់ ក្នុងរយៈពេល ៣ខែ ឬ តិចជាងរយៈពេលដាក់ប្រាក់បញ្ញើ និងដែលងាយប្តូរជាសាច់ប្រាក់ហើយវាមិនមែនជាហានិភ័យដែលធ្ងន់ធ្ងរ នៅពេលតំលៃរបស់វាប្រែប្រួលទេ។

### ២.៣.៦ ប្រាក់បញ្ញើនៅធនាគារ

ប្រាក់បញ្ញើនៅធនាគារនានាត្រូវបានកត់ត្រាតាមតម្លៃដើម។

### ២.៣.៧ ឥណទានអោយអតិថិជន

រាល់ឥណទានអោយអតិថិជន ត្រូវបានបង្ហាញក្នុងតារាងតុល្យការ ជាទឹកប្រាក់ដើម ដោយដកចេញនូវឥណទានដែលត្រូវបានលុបចោល និងសំវិធានធនចំពោះឥណទានបាត់បង់។

ឥណទានត្រូវបានលុបចោល នៅពេលដែលក្រុមហ៊ុនរំពឹងយ៉ាងច្បាស់លាស់ថា ឥណទានមិនអាចប្រមូលមកវិញបាន។ ការប្រមូលបានមកវិញនៃឥណទានដែលត្រូវបានលុបចោល ឬ បានធ្វើសំវិធានធននៅក្នុងការិយបរិច្ឆេទមុនៗ នឹងបន្ថយទឹកប្រាក់នៃសំវិធានធនសំរាប់ឥណទានបាត់បង់នៅក្នុងរបាយការណ៍លទ្ធផល។

រាល់ឥណទានដែលបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់ គឺជាឥណទានមិនដំណើរការ។

#### ២.៣.៧.១ ការធ្វើចំណាត់ថ្នាក់ និង សំវិធានធនលើឥណទានបាត់បង់

ក្រុមហ៊ុនអនុវត្តតាមការកំណត់អំពីចំណាត់ថ្នាក់ឥណទាន និងធ្វើសំវិធានធនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជាតាមប្រកាសលេខ ធ ៧-០២-១៨៦ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២។ ប្រកាសនេះតម្រូវ អោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជា ៤ ថ្នាក់។ កំរិតអប្បបរមាចាំបាច់ នៃការធ្វើសំវិធានធនទូទៅ និងជាក់លាក់ត្រូវបានធ្វើឡើងដោយផ្អែកលើការធ្វើចំណាត់ថ្នាក់ឥណទានមិនរួមបញ្ចូលទ្រព្យសកម្ម ដែលបានសន្យាដាក់បញ្ចាំដូចខាងក្រោម ៖

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃដែលហួសកាលកំណត់សង* | *សំវិធានធន* |
|---|---|---|
| *ឥណទាន (តិចជាង ១ ឆ្នាំ)* | | |
| ឥណទានធម្មតា | គ្មាន | 0% |
| ឥណទានក្រោមស្តង់ដារ | ពី ៣០ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៦០ថ្ងៃ | ១0% |
| ឥណទានជាប់សង្ស័យ | ពី ៦០ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៩០ថ្ងៃ | ៣0% |
| ឥណទានបាត់បង់ | ៩០ថ្ងៃ ឬ ច្រើនជាង | ១00% |

*ឥណទាន (ច្រើនជាង ១ ឆ្នាំ)*

| | | |
|---|---|---|
| ឥណទានធម្មតា | គ្មាន | 0% |
| ឥណទានក្រោមស្តង់ដារ | ពី ៣០ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ១៨០ថ្ងៃ | ១០% |
| ឥណទានជាប់សង្ស័យ | ពី ១៨០ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង៣៦០ថ្ងៃ | ៣០% |
| ឥណទានបាត់បង់ | ៣៦០ថ្ងៃ ឬ ច្រើនជាង | ១០០% |

ការធ្វើសំវិធានធនជាក់លាក់ត្រូវបានគណនាជាភាគរយ នៃឥណទានដែលនៅសល់ត្រឹមពេលដែលឥណទានត្រូវបានចាត់ថ្នាក់ ដោយមិនគិតបញ្ចូលការប្រាក់បង្គរ ហើយកាត់ជាចំណាយ។ ការប្រាក់សំរាប់ឥណទានមិនដំណើរការ មិនត្រូវបានគិតបង្គរឡើយ។

ឥណទានត្រូវបានធ្វើសំវិធានទៅក្នុងរបាយការណ៍លទ្ធផលពេលដែលឥណទានផុតកាលកំណត់ទូទាត់ ១៨០ថ្ងៃសំរាប់ឥណទានរយៈពេល ១ឆ្នាំ ឬ តិចជាង ហើយផុតកាលកំណត់ ៣៦០ថ្ងៃ សំរាប់ឥណទានរយៈពេលច្រើនជាង ១ឆ្នាំ។ ឥណទានត្រូវបានលុបចោល គឺត្រូវបានដកចេញពីបណ្តុំឥណទាននៅសល់ និងការធ្វើសំវិធានធន។

***ឥណទានផុតកាលកំណត់***

អនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ B៧-00-៥១K ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២000 ឥណទានផុតកាលកំណត់ត្រូវបានកំណត់ថាជា ឥណទាននៅសល់សរុបទាំងអស់ដែលទាំងប្រាក់ដើមនិងការប្រាក់បានផុតកំណត់ដោយមិនមានការសំរួលលើលក្ខខណ្ឌទូទាត់។ ជាទូទៅ ឥណទានមិនត្រូវបានអនុញ្ញាតិអោយកែសំរួលលើលក្ខខណ្ឌទូទាត់ឡើយ។

យ៉ាងណាមិញក្នុងករណីកម្រ ឥណទានត្រូវបានគេអនុញ្ញាតិអោយកែសំរួលមួយដងក្នុងមួយខួបឥណទាន។ ការពន្យារពេលអតិបរមាគឺ ត្រឹម ៥ខែ និង ៥០%នៃឥណទានសរុប។

ការធ្វើសំវិធានធនជាក់លាក់ ត្រូវបានគណនាជាភាគរយនៃ ឥណទានដែលនៅសល់ត្រឹមពេលឥណទានត្រូវបានចាត់ថ្នាក់ ដោយមិនគិតបញ្ចូលការប្រាក់បង្គរ។ សំវិធានធនត្រូវបានកត់ត្រាក្នុងគណនីក្រុមហ៊ុន និងសំវិធានទៅក្នុងរបាយការណ៍លទ្ធផលពេលដែលឥណទានត្រូវបានចាត់ថ្នាក់ក្រោមស្តង់ដារ។ ការវិភាគលើឥណទានផុតកំណត់មានបង្ហាញក្នុងកំណត់សំគាល់លេខ ៥។

## *២.៣.៨ អចលនទ្រព្យ និងបរិក្ខារ*

អចលនទ្រព្យ និងបរិក្ខារ ត្រូវបានបង្ហាញជាថ្លៃដើម ដោយដកចេញនូវការប្រើប្រាស់ប្រចាំថ្ងៃដករំលស់បង្គរ និងសំវិធានធនលើការស្រុតចុះនៃថ្លៃ៖ប្រសិនបើមាន៖។ ការផ្លាស់ប្តូរអោយុកាលប្រើប្រាស់ រំពឹងទុកត្រូវបានបង្ហាញ ពីការប្តូរកាលបរិច្ឆេទ ឬវិធីសាស្ត្ររំលស់អោយបានសមស្រប ហើយ អនុវត្តដូចជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យដែរ។

*រំលស់*

រំលស់នៃអចលនទ្រព្យនិងហត្ថូបករណ៍ត្រូវបានគណនាតាមវិធីសាស្ត្រស្មើភាគលើអាយុកាលប្រើប្រាស់ ប៉ាន់ស្មាននៃទ្រព្យសកម្មទាំងអស់នេះ ដែលកំណត់ដូចខាងក្រោម៖

| | |
|---|---|
| ការកែលំអរអគារភតិសន្យា | ៣-១០ឆ្នាំ |
| ហត្ថូបករណ៍ព័ត៌មានវិទ្យា និងកុំព្យូទ័រ | ៣-៥ឆ្នាំ |
| ហត្ថូបករណ៍ការិយាល័យ | ២-៣ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ | ៥ឆ្នាំ |

ប្រភេទនៃអចលនទ្រព្យ និងហត្ថូបករណ៍ ត្រូវបានឈប់ទទួលស្គាល់ នៅពេលលក់ចេញ ឬ នៅពេលមិនមាន អត្ថប្រយោជន៍អនាគត ដែលត្រូវបានរំពឹងទុកពីការប្រើប្រាស់វានោះ។ ការចំណេញ ឬខាតលើការឈប់ ទទួលស្គាល់ទ្រព្យសកម្ម ៉ដែលត្រូវបានគណនាជាចំនួនខុសគ្នារវាងទឹកប្រាក់ដែលទទួលបានពីការលក់សុទ្ធ និងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនោះ៖ ត្រូវបានទទួលស្គាល់ក្នុង ចំណូលអាជីវកម្មផ្សេងៗទៀត នៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលទ្រព្យសកម្មនោះ ត្រូវបានឈប់ទទួលស្គាល់។

## *២.៣.៩ ប្រាក់បញ្ញើនៅធនាគារ*

ប្រាក់បញ្ញើនៅធនាគារនានាត្រូវបានកត់ត្រាតាមតម្លៃដើម។

## *២.៣.១០ គណនីត្រូវទទួលផ្សេងៗ*

គណនីត្រូវទទួលផ្សេងៗរួមទាំងទ្រព្យសកម្មផ្សេងៗត្រូវបានកត់ត្រាទៅតាមតម្លៃ ដែលរំពឹងទុកថាប្រមូលបាន។ ការប៉ាន់ស្មាន ត្រូវធ្វើឡើងសំរាប់បំណុលជាប់សង្ស័យ ដោយផ្អែកលើការពិនិត្យសារឡើងវិញ ចំពោះបរិមាណ នៅសល់នាកាលបរិច្ឆេទតារាងតុល្យការ។

## *២.៣.១១ ប្រាក់បញ្ញើតាមច្បាប់*

ប្រាក់បញ្ញើតាមច្បាប់សំរាប់សកម្មភាពទាក់ទងទៅនឹងក្រុមហ៊ុន ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយ នៃដើមទុនអប្បបរមារបស់ក្រុមហ៊ុន និងប្រាក់បញ្ញើរបស់អតិថិជន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

### ២.៣.១២ ការទទួលស្គាល់ចំណូល និង ចំណាយ

ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលពាក់ព័ន្ធជាមួយប្រតិបត្តិការ នឹងហូរចូលមកក្នុងក្រុមហ៊ុនហើយចំនួនទឹកប្រាក់នៃចំណូលនោះអាចធ្វើការវាស់វែងគួរអោយជឿជាក់បាន។

*ក- ចំណូលពីការប្រាក់ ឬ ចំណាយ*

ចំណូលការប្រាក់បានមកពីការឥណទាន និងសមតុល្យជាមួយធនាគារជាតិ និងធនាគារផ្សេងៗត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ។ ពេលដែលឥណទានមួយក្លាយជាឥណទានមិនដំណើរការ ការប្រាក់ត្រូវបានព្យួរទុកហើយត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់។

ចំណាយត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ។

*ខ- ចំណូលកម្រៃឈ្នួល និងកម្រៃជើងសារ*

ក្រុមហ៊ុនទទួលបានចំណូលពីកម្រៃឈ្នួល និងកម្រៃជើងសារទៅតាមប្រភេទសេវាកម្មផ្តល់ទៅអោយអតិថិជនភាគច្រើនទទួលបានពីដំណើរការឥណទាន និងសន្សំ។

ចំណូលកម្រៃឈ្នួល និងកម្រៃជើងសារត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់។

### ២.៣.១៣ ភាគីពាក់ព័ន្ធ

ភាគីដែលចាត់ទុកថា ជាភាគីពាក់ព័ន្ធលុះត្រាក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រងផ្ទាល់ ឬ ប្រយោលលើភាគីផ្សេងទៀត ឬ មានឥទ្ធិពលយ៉ាងសំខាន់ក្នុងការធ្វើសេចក្តីសំរេចចិត្តផ្នែកហិរញ្ញវត្ថុនិងប្រតិបត្តិការ ផ្ទុយទៅវិញ ប្រសិនបើក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលជាសំខាន់។

ភាគីពាក់ព័ន្ធ អាចជា រូបវន្តបុគ្គល ឬ នីតិបុគ្គល ហើយក៏បានរួមបញ្ចូលផងដែរនូវ បុគ្គលជិតស្និទ្ធនៅក្នុងសមាជិកគ្រួសារផងដែរ។ ភាគីពាក់ព័ន្ធត្រូវដែលបានកំនត់ក្នុងមាត្រា ៤៩ និង ៥០ នៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា រួមមាន៖

ក. រាល់បុគ្គលទាំងឡាយណា ដែលកាន់កាប់ដោយផ្ទាល់ ឬ ប្រយោលនូវភាគហ៊ុន យ៉ាងហោចណាស់ ១០ ភាគរយនៃមូលធន ឬ សិទ្ធិបោះឆ្នោត

ខ. រាល់ក្រុមហ៊ុនទាំងឡាយណា ដែលក្រុមហ៊ុនកាន់កាប់ដោយផ្ទាល់ ឬ ប្រយោល នូវភាគហ៊ុន យ៉ាងហោចណាស់ ១០ ភាគរយនៃមូលធន ឬ សិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន

គ. រាល់បុគ្គលទាំងឡាយណាដែលចូលរួមក្នុងអភិបាលកិច្ច ការចាត់ចែង ការគ្រប់គ្រង ដឹកនាំ ឬ ការត្រួតពិនិត្យផ្ទៃក្នុងនិង

ឃ. រាល់សវនករខាងក្រៅ

## *២.៣.១៤ ពន្ធលើប្រាក់ចំណេញ*

*ពន្ធក្នុងគ្រា*

ពន្ធក្នុងគ្រាលើទ្រព្យសកម្ម និងទ្រព្យអកម្ម សំរាប់ការិយបច្ឆេទគ្រាមុន និងបច្ចុប្បន្នត្រូវបានវាស់វែងជាទឹកប្រាក់ ដែលត្រូវបានរំពឹងទុកថា ត្រូវបានប្រមូលមកវិញ ឬ ត្រូវបង់អោយអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវបានប្រើ ដើម្បីគណនាទឹកប្រាក់ទាំងនេះ គឺជាអត្រា និងច្បាប់ពន្ធដែលមានសុពលភាព រហូតដល់កាលបរិច្ឆេទនៃតារាងតុល្យការ។

*ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានគណនា ដោយប្រើវិធីសាស្ត្របំណុលតុល្យការ លើចំនួនខុសគ្នាបណ្តោះអាសន្ននាកាលបរិច្ឆេទនៃតារាងតុល្យការ រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល ហើយនិងតម្លៃពិតគណនេយ្យរបស់ពួកវាក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យារលើទ្រព្យអកម្មត្រូវបានទទួលស្គាល់លើ ចំនួនខុសគ្នាបណ្តោះអាស ន្ន ជាប់ពន្ធទាំងអស់ លើកលែងតែនៅពេលពន្ធពន្យារលើទ្រព្យអកម្ម កើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬ បំណុលនៅក្នុងប្រតិបត្តិការ ដែលនៅពេលនោះ វាមិនជះឥទ្ធិពលដល់ប្រាក់ចំណេញតាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

ពន្ធពន្យារលើទ្រព្យសកម្មត្រូវបានទទួលស្គាល់សំរាប់ភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ដែលអាចកាត់បន្ថយបានរហូតដល់ទំហំមួយ ដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនឹងអាចមានដើម្បីកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចប្រើប្រាស់បាន លើកលែងតែនៅពេលពន្ធពន្យារលើទ្រព្យសកម្ម កើតឡើងពីការទទួលស្គាល់នាគ្រាដំបូងនៃទ្រព្យសកម្មឬ បំណុល

ក្នុងប្រតិបត្តិការ ដែលនៅពេលប្រតិបត្តិការនោះ មិនមានឥទ្ធិពលដល់ប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

តម្លៃពិតគណនេយ្យនៃពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញ នាកាលបរិច្ឆេទតុល្យការនីមួយៗ ហើយនិងត្រូវបានកាត់បន្ថយមកត្រឹមទំហំមួយ ដែលវាមិនទំនងថាមានប្រាក់ចំណេញ ជាប់ពន្ធគ្រប់គ្រាន់នឹងអាចផ្តល់អោយទ្រព្យសកម្មទាំងអស់ ឬ មួយផ្នែកអាចស្តារមកវិញនាពេលអនាគត។ ពន្ធពន្យារលើប្រាក់ចំណូលពន្យារលើទ្រព្យសកម្ម ដែលមិនត្រូវបានទទួល

ស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញនាកាលបរិច្ឆេទនៃតុល្យការនីមួយៗ ហើយត្រូវបានទទួលស្គាល់តែ ទំហំមួយដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនា ពេលអនាគតនឹងធ្វើអោយពន្ធពន្យារលើទ្រព្យសកម្មនោះ អាចត្រូវបានយកត្រលប់មកវិញ។

### *២.៣.១៥ សំវិធានធនលើបំណុល*

សំវិធានធនលើបំណុល ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់បច្ចុប្បន្នដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាលហើយវាទំនងជាមានលទ្ធភាពដែលតម្រូវអោយមានលំហូរចេញ ផលប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយការប៉ាន់ស្មាន នៃបរិមាណនោះត្រូវបានធ្វើឡើង។

សំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញនាកាលបរិច្ឆេទនីមួយៗនៃតារាងតុល្យការ ហើយធ្វើការកែតម្រូវ អោយស្របទៅនឹងការប៉ាន់ស្មានល្អបំផុតនាពេលបច្ចុប្បន្ន។ នៅពេលតម្លៃ ពេលវេលានៃសាច់ប្រាក់មាន ឥទ្ធិពលជាសារវន្ត បរិមាណសំវិធានធន គឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងទុកដើម្បីទូទាត់បំណុល។

## ៣. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | *២០១១* | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| គណនីចរន្ត | ៧៨៧.០១០ | ៣.១៧៨.៧៣៣ |
| ប្រាក់បញ្ញើធានាលើដើមទុន | ៥០.០០០ | ២០១.៩៥០ |
| | **៨៣៧.០១០** | **៣.៣៨០.៦៨៣** |

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០០-០៦ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ក្រុមហ៊ុនតម្រូវអោយរក្សាប្រាក់បញ្ញើធានាលើដើមទុនសមមូលនឹង ៥ % នៃដើមទុនចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា។ ប្រាក់បញ្ញើនេះមិនអនុញ្ញាតិអោយប្រើប្រាស់សំរាប់ប្រតិបត្តិការប្រចាំថ្ងៃទេ ប៉ុន្តែក្រុមហ៊ុនអាចដកមកវិញបាននៅពេលក្រុមហ៊ុនបញ្ឈប់ប្រតិបត្តិការនៅប្រទេស កម្ពុជាដោយស្ម័គ្រចិត្ត។

ប្រាក់បញ្ញើធានាដើមទុន ទទួលបានការប្រាក់ ៣% ក្នុងមួយឆ្នាំ ខណៈដែលគណនីចរន្តមិនទទួលបានការប្រាក់ឡើយ។

## ៤. សមតុល្យនៅធនាគារផ្សេង

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| គណនីចរន្ត-ដុល្លារអាមេរិក | **៥៨.៦៧៦** | **២៣៦.៩៩២** |

ប្រាក់បញ្ញើនៅធនាគាររួមមានគណនីចរន្តនៅធនាគារក្នុងស្រុក ដែលគ្មានការប្រាក់។

សំរាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមបញ្ចូល ៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| សាច់ប្រាក់ក្នុងដៃ | ៤៨១ | ១.៩៤៣ |
| គណនីចរន្តនៅធនាគារជាតិ | ៧៨៧.០១០ | ៣.១៧៨.៧៣៣ |
| គណនីចរន្តនៅធនាគារផ្សេង | ៥៨.៦៧៦ | ២៣៦.៩៩២ |
| | **៨៤៦.១៦៧** | **៣.៤១៧.៦៦៨** |

## ៥. ឥណទានទៅអតិថិជន

ក-ឥណទានទៅអតិថិជនត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ឥណទានទៅអតិថិជន | ២៩.៤៧៥ | ១១៩.០៥០ |
| ឥណទានទៅនិយោជិក | ៣.៥២៩ | ១៤.២៥៣ |
| | **៣៣.០០៤** | **១៣៣.៣០៣** |

ការវិភាគបន្ថែមលើឥណទានទៅអតិថិជនត្រូវបានកំណត់ដូចខាងក្រោម:

ខ- ការចាត់ថ្នាក់ សំណុំឥណទាន ដូចខាងក្រោម ៖

| | *២០១១* | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ឥណទានធម្មតា ៖ | | |
| មានវត្ថុធានា | - | - |
| គ្មានវត្ថុធានា | ៣៣.០០៤ | ១៣៣.៣០៣ |
| ឥណទានក្រោមស្តង់ដារ ៖ | | |
| មានវត្ថុធានា | - | - |
| គ្មានវត្ថុធានា | - | - |
| ឥណទានជាប់សង្ស័យ ៖ | | |
| គ្មានវត្ថុធានា | - | - |
| មានវត្ថុធានា | - | - |
| ឥណទានបាត់បង់ ៖ | | |
| គ្មានវត្ថុធានា | - | - |
| មានវត្ថុធានា | - | - |
| **ឥណទានសរុប** | **៣៣.០០៤** | **១៣៣.៣០៣** |

ការវិភាគនៃគុណភាពឥណទានស្តង់ដារ យោងទៅកំ ណាត់សំគាល់លេខ ១៤ .១ ស្តីពីហានិភ័យឥណទាន។

គ-សំរាប់ការវិភាគសំណុំឥណទានដល់កាលកំណត់ យោងទៅកំណាត់សំគាល់លេខ១៥ស្តីអំពីការវិភាគសាច់ប្រាក់ងាយស្រួល។

ឃ- ការវិភាគសំណុំឥណទានតាម និវាសនជន ទំនាក់ទំនង និង រូបិយវត្ថុដូចខាងក្រោម៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| **ស្ថានភាពនិវាសនភាពៈ** | | |
| និវាសនជន | ៣៣.០០៤ | ១៣៣.៣០៣ |
| អនិវាសនជន | - | - |
| | **៣៣.០០៤** | **១៣៣.៣០៣** |
| **ទំនាក់ទំនង ៖** | | |
| ភាគីពាក់ព័ន្ធ | - | - |
| មិនមែនភាគីពាក់ព័ន្ធ | ៣៣.០០៤ | ១៣៣.៣០៣ |
| | ៣៣.០០៤ | ១៣៣.៣០៣ |
| **តាមរូបិយប័ណ្ណ ៖** | | |
| ដុល្លារអាមេរិក | ៣៣.០០៤ | ១៣៣.៣០៣ |

អត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោមៈ

| | ២០១១ |
|---|---|
| ឯកត្តបុគ្គល | ២៥% - ៣៥.៨០% |

## ៦. ទ្រព្យសកម្មផ្សេងៗ

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ប្រាក់កក់លើការជួល និងប្រាក់កក់ផ្សេងៗ | ១៦.៧៥៩ | ៦៧.៦៩០ |
| ប្រាក់បង់មុន | ៩.៦៦៤ | ៣៩.០៣៣ |
| ការប្រាក់ត្រូវទទួល | ៨៥ | ៣៤៣ |
| | **២៦.៥០៨** | **១០៧.០៦៦** |

## ៧. អចលនទ្រព្យ និងបរិក្ខារ

| | *ការកែលំអរអគារ* | *សម្ភារៈ និងគ្រឿងបំពាក់* | *បរិក្ខារការិយាល័យ* | *បរិក្ខារព័ត៌មានវិទ្យា និងកុំព្យូទ័រ* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| ***តម្លៃដើម ៖*** | | | | | |
| នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០១១ | | | | | |
| ការទិញបន្ថែម | ៧.៧៧៦ | ៦.៥៥៧ | ៦.៧៨៩ | ៦០.៨០១ | ៨១.៩២៣ |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១១ | **៧.៧៧៦** | **៦.៥៥៧** | **៦.៧៨៩** | **៦០.៨០១** | **៨១.៩២៣** |
| **រំលស់បង្គរ ៖** | | | | | |
| នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០១១ | - | - | - | - | - |
| រំលស់ប្រចាំឆ្នាំ | ២៦៧ | ៥៣៩ | ៨៨២ | ២.២៦៣ | ៣.៩៥១ |
| នៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១១ | **២៦៧** | **៥៣៩** | **៨៨២** | **២.២៦៣** | **៣.៩៥១** |
| ***តម្លៃពិតគណនេយ្យ៖*** | | | | | |
| នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១១ | **៧.៥០៩** | **៦.០១៨** | **៥.៩០៧** | **៥៨.៥៣៨** | **៧៧.៩៧២** |
| សមមូលពាន់រៀល *(កំណត់សំគាល់លេខ ២.៣.១)* | **៣០.៣២៩** | **២៤.៣០៧** | **២៣.៨៥៨** | **២៣៦.៤៣៥** | **៣១៤.៩២៩** |

## ៨. គណនីត្រូវសង

| | *២០១១* | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សំគាល់លេខ ២.៣.១)* |
| អចលនទ្រព្យ និងបរិក្ខារ | ៥៦.៥២៣ | ២២៨.២៩៦ |
| ឈ្មួញបោះដុំ | ២៤.៤១០ | ៩៨.៥៩២ |
| ផ្សេងៗ | ២.៩២៨ | ១១.៨២៦ |
| | **៨៣៨៦១** | **៣៣៨៧១៤** |

## ៩. មូលធន

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| បោះផ្សាយនិងបង់ទាំងស្រុង | **១.០០០.០០០** | **៤.០៣៩.០០០** |

## ១០. ចំណាយប្រតិបត្តិការ

| | សំរាប់ការិយបរិច្ឆេទចាប់ពី ថ្ងៃទី ៥ តុលា ដល់ថ្ងៃទី ៣១ ធ្នូ ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ចំណាយបុគ្គលិក | ៥៣.៤២១ | ២១៥.៧៦៧ |
| ចំណាយមុនប្រតិបត្តិការ | ៩.៦៦៤ | ៣៩.០៣៣ |
| ចំណាយធ្វើដំណើរ | ៦.៤៥៦ | ២៦.០៧៦ |
| ចំណាយផ្សាយពាណិជ្ជកម្ម | ៥.៩៦៥ | ២៤.០៩៣ |
| ចំណាយវិជ្ជាជីវៈ | ៤.៦៧៩ | ១៨.៨៩៨ |
| ចំណាយរំលស់ | ៣.៩៥១ | ១៥.៩៥៨ |
| ចំណាយជួលអគារ | ៣.៥២០ | ១៤.២១៧ |
| សំភារៈការិយាល័យ និង បោះពុម្ព | ២.៨៩៣ | ១១.៦៨៥ |
| ចំណាយជួសជុល និង ថែទាំ | ២.៣៧៥ | ៩.៥៩៣ |
| ចំណាយយានយន្ត | ១.៩០៨ | ៧.៧០៦ |
| ចំណាយទូរគមនាគមន៍ | ១.៤៦១ | ៥.៩០១ |
| ចំណាយទឹកភ្លើង | ១.១២០ | ៤.៥២៤ |
| ចំណាយផ្សេងៗ | ៣.១៦៩ | ១២.៨០០ |
| | **១០០.៥៨២** | **៤០៦.២៥១** |

## ១១. ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនតំណាងដោយពន្ធអប្បបរមាសំរាប់ការិយបរិច្ឆេទ។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុនគឺជា កម្មវត្ថុនៃការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានពន្ធដារ។ តួលេខ បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចមានការប្រែប្រួលនៅពេលក្រោយ ខណៈដែលមានការសំរេចចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ ដោយសារតែការអនុវត្តន៍ច្បាប់ និង បទបញ្ញត្តិពន្ធដារមានការបកស្រាយផ្សេងៗគ្នា។

*អត្រាពន្ធដែលអនុវត្តន៍*

យោងតាមច្បាប់សារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញអត្រាពន្ធ ២០% នៃប្រាក់ចំណេញជាប់ពន្ធ។

ក្រៅពីពន្ធលើប្រាក់ចំណេញ
អ្នកជាប់ពន្ធនៅប្រទេសកម្ពុជាត្រូវជាប់ពន្ធអប្បបរមាដាច់ដោយឡែកមួយ ទៀត។ ពន្ធអប្បបរមាគឺជាពន្ធប្រចាំឆ្នាំដែលស្មើ ១ភាគរយនៃផលរបរសរុបជាមួយពន្ធទាំងអស់លើក លែងអាករលើតំលៃបន្ថែមដោយមិនគិតថាអ្នកជាប់ពន្ធចំណេញ ឬ ខាត។ ពន្ធអប្បរមាសំរាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ៥ ខែតុលា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ត្រូវបានកំណត់យក ១% នៃចំណូល។

## ១២. ការធានាចំណាយ

ក្រុមហ៊ុនជួលអាគារក្រោមកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការដោយមានការធានាចំណាយដូចខាងក្រោម៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ក្នុងអំឡុងពេល ១ ឆ្នាំ | ១៩.២០០ | ៧៧.៥៤៩ |
| ចាប់ពី ២ ឆ្នាំ ដល់ ៣ឆ្នាំ | ១២.៨០០ | ៥១.៦៩៩ |
| | **៣២.០០០** | **១២៩.២៤៨** |

## ១៣. ប្រតិបត្តិការ និងសមតុល្យរបស់ភាគីពាក់ព័ន្ធ

ក- សមតុល្យជាមួយភាគីពាក់ព័ន្ធ

| *ភាគីពាក់ព័ន្ធ* | *ប្រតិបត្តិការ* | *២០១១* | |
|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ACS Capital Corporation Limited | ផ្ទេរទ្រព្យសកម្ម | ២៣.៩២៨ | ៩៦.៦៩៥ |
| AEON Credit Service Co., Ltd | ទូទាត់ចំណាយជំនួស | ២១.៩៣៣ | ៨៨.៥៨៨ |
| | | **៤៥.៨៦១** | **១៨៥.៥៣៣** |

ខ- អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាលរួមបញ្ចូលទាំងអត្ថប្រយោជន៍ផ្សេងៗរបស់ក្រុមប្រឹក្សាភិបាលសំរាប់ ការិយបរិច្ឆេទមានចំនួន ៣២.៩៨៣ដុល្លារអាមេរិក ឬ ១៣៣.២១៩.០០០រៀល។

## ១៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពក្រុមហ៊ុន ឆ្លុះបញ្ចាំងពីហានិភ័យហិរញ្ញវត្ថុជាច្រើន ៖ ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមាន ហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ និង ហានិភ័យថ្លៃ) និង ហានិភ័យសាច់ប្រាក់ងាយស្រួល។ ការទទួលយកហានិភ័យ គឺជាស្នូលនៃពាណិជ្ជកម្មហិរញ្ញវត្ថុ ហើយហានិភ័យប្រតិបត្តិការ គឺជាហានិភ័យ មួយដែលមិនអាចជៀសរួច ពេលធ្វើពាណិជ្ជកម្ម។

ក្រុមហ៊ុន មិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ ដូចជាកិច្ចសន្យាការប្តូរប្រាក់បរទេស និង កិច្ចសន្យាទប់ស្កាត់អត្រាការប្រាក់ ដើម្បីគ្រប់គ្រងការប្រឈមហានិភ័យ របស់ខ្លួនឡើយ។

ក្រុមហ៊ុន មានបំណងអនុវត្តតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា សំរាប់គោលបំណង គ្រប់គ្រង ហានិភ័យហិរញ្ញវត្ថុ។ ម្យ៉ាងទៀតក្រុមហ៊ុនក៏ទទួលស្គាល់ថា ការអនុវត្តន៍ល្អបំផុតជាលក្ខណៈអន្តរជាតិលើការគ្រប់គ្រងហានិភ័យ ត្រូវបានអនុវត្តអោយបានពេញលេញ។ ក្រុមប្រឹក្សាភិបាលបានបង្កើតផ្នែក គ្រប់គ្រងហានិភ័យ ដើម្បីបង្កើតអោយមានព្រំដែនវិសាលភាពនៃការទទួល យកហានិភ័យសំរាប់ក្រុមហ៊ុន និងអង្កេតមើលសកម្មភាពទាំងឡាយប្រឆាំងនឹងព្រំដែនទាំងនោះ។

ក្រុមហ៊ុនមានទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុខាងក្រោម ៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨១ | ១.៩៤៣ |
| សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | ៨៣៧.០១០ | ៣.៣៨០.៦៨៣ |
| សមតុល្យនៅធនាគារផ្សេងៗ | ៥៨.៦៧៦ | ២៣៦.៩៩២ |
| ឥណទានទៅអតិថិជន | ៣៣.០០៤ | ១៣៣.៣០៣ |
| ទ្រព្យសកម្មផ្សេងៗ | ១៦.៨៤៤ | ៦៨.០៣៣ |
| **សរុបទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់** | **៩៤៦.០១៥** | **៣.៨២០.៩៥៤** |
| **ទ្រព្យអកម្មហិរញ្ញវត្ថុ** | | |
| គណនីត្រូវសង | ៨៣.៨៦១ | ៣៣៨.៧១៤ |
| ជំពាក់ទៅភាគីពាក់ព័ន្ធ | ៤៥.៨៦១ | ១៨៥.២៣៣ |
| **សរុបបំណុលហិរញ្ញវត្ថុទាំងអស់** | **១២៩.៧២២** | **៥២៣.៩៤៧** |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **៨១៦.២៩៣** | **៣.២៩៧.០០៧** |

## ១៤.១ ហានិភ័យឥណទាន

ក្រុមហ៊ុនប្រឈមនឹង ហានិភ័យឥណទាន ដែលជាហានិភ័យដែលភាគីពាក់ព័ន្ធនឹងអាចធ្វើអោយមានការខាតបង់ហិរញ្ញវត្ថុចំពោះក្រុមហ៊ុន ដោយការមិនអនុវត្តនូវកាតព្វកិច្ច។ ហានិភ័យឥណទានគឺជាហានិភ័យសំខាន់បំផុតសំរាប់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ការប្រឈមឥណទាន កើតឡើងជាសំខាន់ក្នុងសកម្មភាពផ្តល់ប្រាក់កម្ចីដែលនាំអោយមានការផ្តល់ឥណទាន ដល់អតិថិជនជាច្រើន។ ការគ្រប់គ្រងហានិភ័យឥណទានអនុវត្តដោយផ្នែកគ្រប់គ្រងហានិភ័យ របស់ក្រុមហ៊ុន។

ក-ការវាស់វែងហានិភ័យឥណទាន

ក្រុមហ៊ុនវាយតម្លៃពីលទ្ធភាពនៃការមិនសងបំណុល របស់បុគ្គលដែលពាក់ព័ន្ធ ដោយយោងទៅលើគោលនយោបាយនីតិវិធី និង ការអនុវត្តន៍ឥណទានទាំងឡាយ។

ខ-ការត្រួតពិនិត្យដែនកំណត់នៃហានិភ័យ និងគោលនយោបាយទប់ស្កាត់

ក្រុមហ៊ុនធ្វើប្រតិបត្តិការផ្តល់ឥណទាន អោយទៅរូបវន្តបុគ្គល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនគ្រប់គ្រង កំណត់ និងត្រួតពិនិត្យនូវការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលណាក៏ដោយដែលហានិភ័យឥណទាន ត្រូវបានកំណត់អត្តសញ្ញាណ។ ចំនួនហានិភ័យ ឥណទានធំៗ ត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ជាឥណទានទាំងមូល ផ្តល់អោយទៅអ្នកទទួលប្រយោជន៍ណាម្នាក់ ដែលមានចំនួនទឹកប្រាក់លើស ២% នៃឥណទានបុគ្គល និង ៣% សំរាប់ឥណទានជាក្រុម នៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដោយអនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៣ ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

គ-គោលនយោបាយនៃការស្រុតថ្លៃទ្រព្យសកម្ម និងសំវិធានធន

ក្រុមហ៊ុនត្រូវបានតំរូវអោយអនុវត្តតាមចំណាត់ថ្នាក់ឥណទាន ដែលត្រូវបានកំណត់ និងធ្វើសំវិធានធនស្របតាមប្រកាសពាក់ព័ន្ធ ដូចដែលបានលាតត្រដាង ក្នុងកំណត់សំគាល់លេខ ២.៣.៧.១។

ឃ- ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ត្រូវបានសង្ខេបដូចខាងក្រោម ៖

| | ២០១១ | |
|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(កំណត់សំគាល់លេខ ២.៣.១)* |
| ឥណទាន និងបុរេប្រទាន មិនហួសកំណត់ និង មិនបាត់បង់តំលៃ (ក) | ៣៣.០០៤ | ១៣៣.៣០៣ |
| ឥណទាន និងបុរេប្រទាន ហួសកំណត់ តែមិនបាត់បង់តំលៃ (ខ) | - | - |
| ឥណទាន និងបុរេប្រទានបាត់បង់ម្នាក់ៗ (គ) | - | - |
| **ឥណទាន និងបុរេប្រទានសរុប** | **៣៣.០០៤** | **១៣៣.៣០៣** |

សំរាប់គោលបំណងនៃសំវិធានធនឥណទាន ការប្រមូលមកវិញពីទ្រព្យបញ្ចាំ (លើកលែងសាច់ប្រាក់) ដោយរំពឹងទុក មិនត្រូវបានយកមកពិចារណាឡើយដោយផ្អែកតាមតំរូវការរបស់ធនាគារជាតិនៃកម្ពុជា ។

ក - ឥណទាន និងបុរេប្រទាន មិនហួសកំណត់ និង មិនបាត់បង់តំលៃ

ឥណទាន និងបុរេប្រទានមិនហួសកំណត់ មិនត្រូវបានចាត់ទុកថាបាត់បង់តំលៃឡើយ លុះត្រាណាមានពិតមានផ្សេងទៀត បង្ហាញពីភាពផ្ទុយគ្នា។

ខ- ឥណទាន និងបុរេប្រទាន ហួសកំណត់ ប៉ុន្តែមិនបាត់បង់តំលៃ

ឥណទាន និងបុរេប្រទានហួសកំណត់រយពេលតិចជាង ៣០ថ្ងៃ មិនត្រូវបានចាត់ទុកថាបាត់បង់តំលៃឡើយ លុះត្រាណាមានពិតមានផ្សេងៗទៀត បង្ហាញពីភាពផ្ទុយគ្នា។

គ- ឥណទាន និងបុរេប្រទាន បាត់បង់តំលៃម្នាក់ៗ

យោងតាមប្រកាសលេខ ធ៧-០២-១៨៦ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីអំពីការចាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យ ឥណទាននិងបុរេប្រទានហួសកំណត់រយះពេលច្រើនជាង ៣០ថ្ងៃ ត្រូវបានចាត់ទុកថាបាត់បង់តំលៃ ហើយកំរិតអប្បបរមានៃការធ្វើសំវិធានធនជាក់លាក់ សំរាប់ការបាត់បង់តំលៃត្រូវបានធ្វើឡើងផ្អែកតាមការចាត់ថ្នាក់ដែលពាក់ព័ន្ធ លុះត្រាណាមានពិតមានផ្សេងទៀត បង្ហាញពីភាពផ្ទុយគ្នា។

## ១៤.២ ហានិភ័យទីផ្សារ

ក្រុមហ៊ុន ប្រឈមនឹងលើការលេចឡើងនូវហានិភ័យទីផ្សារដែលជាហានិភ័យ ធ្វើអោយតម្លៃទីផ្សារសមស្រប ឬ លំហូរសាច់ប្រាក់នាអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុ មានការប្រែប្រួលដោយសារតែប្រែប្រួលក្នុងតម្លៃទីផ្សារ។ ហានិភ័យទីផ្សារ កើតឡើងពីបំរែបំរួលនៃអត្រាការប្រាក់ និង រូបិយប័ណ្ណ ដែលទាំងអស់នេះ ត្រូវបានបង្ហាញជាការបំរែបំរួលទីផ្សារ ជាក់លាក់ និងទូទៅ ហើយនឹងជាការប្រែប្រួលក្នុងកំរិតអស្ថិរភាពនៃអត្រា ឬ តម្លៃទីផ្សារ ដូចជាអត្រាការប្រាក់ការពន្យារ ឥណទាន អត្រាប្តូរប្រាក់បរទេស និងតំលៃមូលនិធិម្ចាស់ហ៊ុន។

ក្រុមហ៊ុនមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ ដូចជាកិច្ចសន្យាទប់ស្កាត់ ការប្តូរប្រាក់ បរទេស និងកិច្ចសន្យាទប់ស្កាត់អត្រាការប្រាក់ ដើម្បីទប់ស្កាត់នូវការលេចឡើងនៃហានិភ័យទាំង នេះទេ។

១.ហានិភ័យប្តូរប្រាក់បរទេស

ក្រុមហ៊ុន ធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការរូបិយប័ណ្ណជាច្រើនប្រភេទ និងត្រូវប្រឈមនូវហានិភ័យរូបិយប័ណ្ណផ្សេងគ្នាជាដំបូង ទាក់ទង នឹងរូបិយប័ណ្ណដុល្លារអាមេរិក។

ហានិភ័យប្តូរប្រាក់បរទេស កើតឡើងពីប្រតិបត្តិការពាណិជ្ជកម្មអនាគត និង ទ្រព្យសកម្ម និង ទ្រព្យអកម្ម ដែលត្រូវបានទទួលស្គាល់ជារូបិយប័ណ្ណមួយដែលមិនមែនជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។

សមតុល្យរូបិយប័ណ្ណនៃទ្រព្យសកម្ម និងទ្រព្យអកម្មបានប្តូរជារូបិយវត្ថុ ផ្សេងក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក ដែលមិនសំខាន់ សំរាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១។ ដូច្នេះគ្មានការវិភាគលើការប្រែប្រួលឡើងចុះណាសំរាប់ហានិភ័យអត្រារបស់រូបិយប័ណ្ណបរទេសត្រូវបានលើកយកមកបង្ហាញទេ។

២-ហានិភ័យតម្លៃ

ក្រុមហ៊ុនមិនត្រូវប្រឈមចំពោះហានិភ័យថ្លៃមូលប័ត្រទេ ពីព្រោះក្រុមហ៊ុនមិនបានកាន់កាប់វិនិយោគណាមួយដែលបានចាត់ថ្នាក់នៅក្នុងតារាងតុល្យការ មូលប័ត្រដែលអាចលក់បាន ឬ មូលប័ត្រជាតម្លៃទីផ្សារសមស្របដែលត្រូវទទួលស្គាល់ថាចំណេញ ឬ ខាត។

៣-ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់តាមលំហូរសាច់ប្រាក់ គឺជាហានិភ័យដែលលំហូរសាច់ប្រាក់អនាគតនៃឧបករណ៍ហិរញ្ញវត្ថុ នឹងប្រែប្រួលដោយសារតែការប្រែប្រួលអត្រាការប្រាក់ទីផ្សារ។ ហានិភ័យអត្រាការប្រាក់តាមតម្លៃទីផ្សារ គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ នឹងប្រែប្រួលដោយសារតែការ ប្រែប្រួលអត្រាការប្រាក់ទីផ្សារ។ តំលៃបន្ថែមការប្រាក់ អាចកើនឡើងដោយសារតែការប្រែប្រួល និងអាចបន្ថយការខាតក្នុងព្រឹត្តិការណ៍ នៅពេលបំរែបំរួលដែលមិនរំពឹងទុកកើតឡើង។ នៅជំណាក់កាលនេះ ថ្នាក់ដឹកនាំក្រុមហ៊ុនមិនមានគោលនយោបាយណាមួយដើម្បីដាក់កំណត់លើ កំរិតមិនត្រូវគ្នានៃការកំណត់ថ្លៃអត្រាការប្រាក់ឡើងវិញអោយនៅក្រោមការគ្រប់គ្រងឡើយ។ ទោះយ៉ាងណា ថ្នាក់ដឹកនាំជាធម្មតា ក៏ត្រួតពិនិត្យមើលលើភាពមិនត្រូវគ្នានេះដែរ ។

ហានិភ័យអត្រាការប្រាក់ កើតឡើងពីលទ្ធភាពនៃការប្រែប្រួលក្នុងអត្រាការប្រាក់នឹងជះឥទ្ធិពលដល់លទ្ធភាពប្រាក់ចំណេញនាពេលអនាគត ឬ តម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ។ ក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យអត្រាការប្រាក់ ជាលទ្ធផលនៃភាពមិនត្រូវគ្នានៃការកំណត់ថ្លៃអត្រាការប្រាក់សារជាថ្មីរបស់ទ្រព្យសកម្ម និង បំណុល។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យនេះដោយ

ផ្គូរផ្គង ការកំណត់ថ្លៃទ្រព្យសកម្ម និង ទ្រព្យអកម្មឡើងវិញ តាមរយៈយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ។

តារាងនេះរួមមាន ឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបង្ហាញជាតម្លៃពិត រៀបតាមប្រភេទរបស់កិច្ចសន្យា ដែលត្រូវបានកំណត់ថ្លៃឡើងវិញ ឬ ក៏តាមកាលអវសានរបស់ពួកវា។

ក្រុមហ៊ុនពុំមានទ្រព្យសកម្ម និង ទ្រព្យអកម្មហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួលទេ។

សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា សមតុល្យជាមួយធនាគារផ្សេងៗរកចំណូលបានអត្រាការប្រាក់ថេរក្នុងអំឡុងពេលនៃការដាក់ប្រាក់ ឥណទានទៅអតិថិជន ទទួលបាននូវអត្រាការប្រាក់ថេរតាមរយសមតុល្យដែលនៅសល់លើលក្ខខ័ណ្ឌព្រមព្រៀងគ្នា ។

## ១៤.៣ ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលក្រុមហ៊ុនមិនអាចមានលទ្ធភាពសងបំណុលរបស់ខ្លួនដែលពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុ នៅពេលបំណុលហិរញ្ញវត្ថុទាំងនោះដល់កាលកំណត់សង និងក្រុមហ៊ុនមិនអាចមានលទ្ធភាពបំពេញនូវមូលនិធិគ្រប់គ្រាន់ទៅអោយអតិថិជន នៅពេលពួកគេមកដកប្រាក់។ មូលហេតុទាំងនេះ ធ្វើអោយក្រុមហ៊ុនខកខានក្នុងការបំពេញកាតព្វកិច្ចសងប្រាក់បញ្ញើជូនអតិថិជន អោយបានទាន់ពេលវេលា
និងខកខានក្នុងការបំពេញកាតព្វកិច្ចផ្តល់កម្ចី។

ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលរបស់ តារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំ និងព័ត៌មាននៃកាលអវសានរបស់បំណុល។ ការត្រួតពិនិត្យ និងការរាយការណ៍មានលក្ខណៈជាស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃ និងរៀបចំគំរោងសំរាប់ថ្ងៃបន្ទាប់ សប្តាហ៍បន្ទាប់ និង ខែបន្ទាប់ដោយរំពឹងទុកពីព្រោះរយៈពេលទាំងនេះជាការិយបរិច្ឆេទគន្លឹះដ៏សំខាន់សំរាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ ថ្នាក់ដឹកនាំត្រួតពិនិត្យបំរែបំរួលរបស់ម្ចាស់ប្រាក់បញ្ញើសំខាន់ៗ និងការរៀបចំអំពីការដកប្រាក់របស់ពួកគេ។

តារាងក្នុងកំណត់សំគាល់លេខ ១៤ គឺជាការវិភាគពីទ្រព្យសកម្ម និងទ្រព្យអកម្ម របស់ក្រុមហ៊ុនតាមកាលអវសានដែលពាក់ព័ន្ធ ដោយផ្អែក លើការិយបរិច្ឆេទនៅសល់នាកាលបរិច្ឆេទតុល្យការទៅនឹងកាលបរិច្ឆេទ កាលអវសានដែលជាប់កិច្ចសន្យា ឬ តាមការប៉ាន់ស្មាន ។

## ១៤.៤ តម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង ទ្រព្យអកម្មហិរញ្ញវត្ថុ

តម្លៃទីផ្សារ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មអាចត្រូវបានប្តូរ ឬ ទ្រព្យអកម្មត្រូវបានទូទាត់តាមមូលដ្ឋានធម្មតា។ តម្លៃទីផ្សារមិនអាចធ្វើទៅបានទាក់ទង ទៅនឹងផ្នែកដ៏សំខាន់ នៃទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយសារតែតម្លៃទីផ្សារដែលអាច ផ្ទៀងផ្ទាត់បានមិនមាននោះទេ។ ហេតុនេះតម្លៃទីផ្សារ ត្រូវបានផ្អែកលើការសន្មតគ្រប់គ្រងជាច្រើនដោយយោងតាមព័ត៌មាននៃមូលដ្ឋានទ្រព្យសកម្ម និងទ្រព្យអកម្ម។ តាមទស្សនៈរបស់ថ្នាក់ដឹកនាំតម្លៃពិត

គណនេយ្យនៃទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលមានក្នុងតារាងតុល្យការគឺជាការប៉ាន់ស្មាន ដ៏សមហេតុផលនៃតម្លៃទីផ្សារ។ ក្នុងការធ្វើការវាយតំលៃនេះ ថ្នាក់ដឹកនាំសន្មត់ថាឥណទាន ទៅអតិថិជនត្រូវបានរក្សាទុកដល់កាលអវសាន្តជាមួយនឹងតម្លៃទីផ្សារ ស្មើនឹងតម្លៃពិតគណនេយ្យនៃប្រាក់អោយខ្ចីទៅអតិថិជន ដែលត្រូវបានធ្វើការកែតំរូវសំវិធានធនសំរាប់ឥណទានបាត់បង់ ប្រសិនបើមាន។

## ១៥. ហានិភ័យសាច់ប្រាក់ងាយស្រួល

តារាងខាងក្រោមបង្ហាញពីអាយុកាលនៃទ្រព្យសកម្ម និង ទ្រព្យអកម្មហិរញ្ញវត្ថុនៃក្រុមហ៊ុន ផ្អែកតាមយៈពេលនៅសល់ ក្នុងការទូទាត់សង។

| | *រហូតដល់ ១ខែ* | *>១-៣ ខែ* | *>៣-១២ ខែ* | *>១ -៥ឆ្នាំ* | *លើសពី ៥ ឆ្នាំ* | *គ្មានកំណត់ កាលអវសាន្ត* | *សរុប* |
|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| នាថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ ២០១១ | | | | | | | |
| *ទ្រព្យសកម្ម* | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៨១ | - | - | - | - | - | ៤៨១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧៨៧.០១០ | - | - | - | - | ៥០.០០០ | ៨៣៧.០១០ |
| សមតុល្យនៅធនាគារផ្សេងៗ | ៥៨.៦៧៦ | - | - | - | - | - | ៥៨.៦៧៦ |
| ឥណទានទៅអតិថិជន | ៤០៨ | ៥.១៨៥ | ២១.៦៣៩ | ៥.៧៧២ | - | - | ៣៣.០០៤ |
| ទ្រព្យសកម្មផ្សេងៗ | ៨៥ | - | - | ១៦.៧៥៩ | - | - | ១៦.៨៤៤ |
| ***សរុបទ្រព្យសកម្មទាំងអស់*** | **៨៤៦.៦៦០** | **៥.១៨៥** | **២១.៦៣៩** | **២២.៥៣១** | **-** | **៥០.០០០** | **៩៤៦.០១៥** |
| *ទ្រព្យអកម្ម* | | | | | | | |
| គណនីត្រូវសង | - | ៨៣.៨៦១ | - | - | - | - | ៨៣.៨៦១ |
| ជំពាក់ទៅភាគីពាក់ព័ន្ធ | ៤៥.៨៦១ | - | - | - | - | - | ៤៥.៨៦១ |
| **សរុបទ្រព្យអកម្មទាំងអស់** | **៤៥.៨៦១** | **៨៣.៨៦១** | **-** | **-** | **-** | **-** | **១២៩.៧២២** |
| **គំលាតសាច់ប្រាក់ងាយស្រួលសុទ្ធ ដុល្លារអាមេរិក** | **៨០០.៧៩៩** | **(៧៨.៦៧៦)** | **២១.៦៣៩** | **២២.៥៣១** | **-** | **៥០.០០០** | **៨១៦.២៩៣** |
| **សមតុល្យ-ពាន់រៀល** *(កំណត់សំគាល់ ២.៣.១)* | **៣.២៣៤.៤២៧** | **(៣១៧.៧៧២)** | **៨៧.៤០០** | **៩១.០០២** | **-** | **២០១.៩៥០** | **៣.២៩៧.០០៧** |

## ១៦. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទតុល្យការ

ក្រៅពីការលាតត្រដាងខាងលើ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺមិនមានព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ហើយមានឥទ្ធិពលខ្លាំងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មកត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១។